# I .ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រម

### ព្រះរាជក្រមលេខ នស/រកម/០៥៩៥/០២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

******

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីប្រកាសបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការផ្តល់សច្ចាប័ន លើកិច្ចព្រមព្រៀង ឥណទាន ចុះថ្ងៃ ទី ០៣ ខែ មីនា ឆ្នាំ ១៩៩៥ រវាងព្រះរាជាណាចក្រកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
# ស្ដីពី
# ការផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងឥណទាន
# ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៥
# រវាងព្រះរាជាណាចក្រកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ី

**មាត្រា ១:** ផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងឥណទានដែលរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ខ្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នូវទឹកប្រាក់ចំនួន ១៩.១៩៧.000 SDR (ដប់ប្រាំបួនលានមួយ រយកៅសិបប្រាំពីរពាន់ អេស ឌី អរ ) តាមឥណទានលេខ ១៣៤៥ CAM (SF) ដើម្បីបំរើគំរោងការ ស្ដារនិងអភិវឌ្ឍន៍អគ្គិសនី ។

**មាត្រា ២:** ច្បាប់នេះត្រូវបានប្រកាសជាប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

**នរោត្តម សីហនុ**

* * *

# ២-ព្រះរាជក្រឹត្យ

## ព្រះរាជក្រឹត្យលេខ នស/រកត/០៥៩៥/៤៥

## យើង

**ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

– បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣